ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 06 / 2012
ម៉ោង (Time/Heure): 14:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ច័ន្ទ ទី ២១ ខែ ឧសភា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៦២

រៀបចំដោយ: ឌុច ផារី និង Matteo CRIPPA

| |
|---|
| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោក Matteo CRIPPA |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក ច័ន្ទ តារាស្មី, លោក William SMITH, លោកVincent DE WILDE D'ESTMAEL |
| ជនជាប់ចោទ៖ អៀង សារី (អវត្តមាន), នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Michiel PESTMAN |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |

| |
|---|
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក ឡោ ជុនធី, លោកស្រី ស៊ិន សុវ៉ន, លោកស្រី ទី ស្រីនណា, លោក Barnabé NEKUIE , លោកស្រី មេធាវី Laure DESFORGES, លោក Pascal AUBOIN |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោក Philippe GOUT |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ៩.៣០ | បញ្ចប់ម៉ោង៖ ៩.៥០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ២០ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការស្នើសុំទទួលស្គាល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីថ្មី (លោកស្រី Laure DESFORGES) | មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី<br>អង្គជំនុំជម្រះ | ៩.៣០ | ៩.៣១ |
| ការអានរបាយការណ៍ពេទ្យទាក់ទងនឹងស្ថានភាពសុខភាពរបស់លោក អៀង សារី | ក្រឡាបញ្ជីអង្គជំនុំជម្រះ | ៩.៣២ | ៩.៣៤ |
| គោលជំហររបស់ភាគីអំពីស្ថានភាពរបស់លោក អៀង សារី | អង្គជំនុំជម្រះ | ៩.៣៤ | ៩.៤២ |
| ការកត់សម្គាល់ទាក់ទងនឹងអវត្តមានរបស់លោក អៀវ សារី | អង្គជំនុំជម្រះ | ៩.៤២ | ៩.៤៥ |
| ការផ្អាកកិច្ចដំណើរការសវនាការរហូតដល់ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១២ | អង្គជំនុំជម្រះ | ៩.៤៦ | ៩.៥០ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការស្នើសុំទទួលស្គាល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីថ្មី (លោកស្រី Laure DESFORGES)**

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិឡើងស្នើសុំទទួលស្គាល់មេធាវីអន្តរជាតិថ្មីដែលតំណាងដើមបណ្តឹងរដ្ឋប្បវេណី (លោកស្រី Laure DESFORGES) ។ អង្គជំនុំជម្រះសម្រេចទទួលស្គាល់លោកស្រី Laure DESFORGES ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**ការអានរបាយការណ៍ពេទ្យទាក់ទងនឹងស្ថានភាពសុខភាពរបស់លោក អៀង សារី**

ក្រឡាបញ្ជីអានរបាយការណ៍សុខភាពរបស់ជនជាប់ចោទ អៀង សារី អំពីស្ថានភាពសុខភាពរបស់គាត់ក្រោយពេលដែលគាត់ត្រូវបានបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យកាលពីថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១២ (ឯកសារ E11/70/2)។

**គោលជំហររបស់ភាគីទាក់ទងនឹងស្ថានភាពរបស់លោក អៀង សារី**

គ្រប់ភាគីទាំងអស់យល់ថា អនុលោមតាមវិធាន ៨១ នីតិវិធីមិនអាចបន្តទៅមុខទៀតនោះទេ គួររង់ចាំរហូតដល់លោក អៀង សារី ត្រឡប់មកវិញ ឬអាចបន្តបានក្នុងករណីដែលគាត់លះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ក្នុងពេលសវនាការ ។

**ព័ត៌មានទាក់ទងនឹងសុខភាពរបស់លោក អៀង សារី និងការទំនាក់ទំនងជាមួយគាត់**

ចៅក្រម Cartwright ស្នើឱ្យមេធាវីការពារក្តី អៀង សារី ធ្វើការបញ្ជាក់លើពីរចំណុចៈទីមួយ ថាតើមេធាវីជំទាស់ដែរឬទេ ប្រសិនបើអង្គជំនុំជម្រះផ្តល់នូវព័ត៌មានពេញលេញអំពីស្ថានភាពសុខភាពរបស់លោក អៀង សារី ដល់សាធារណៈជននោះ ។ ទីពីរ ថាតើមេធាវីមានការលំបាកក្នុងការទាក់ទងជាមួយនឹងកូនក្តីរបស់ខ្លួនដែរឬទេ ។ មេធាវីការពារក្តីបញ្ជាក់ថា ចំពោះបញ្ហាទីមួយគាត់នឹងសួរបញ្ជាក់ទៅកូនក្តីរបស់គាត់ ប៉ុន្តែ មេធាវីយល់ថា កូនក្តីរបស់គាត់ប្រហែលជាមិនជំទាស់ទៅនឹងការផ្តល់ព័ត៌មានពេញលេញអំពីបញ្ហាសុខភាពរបស់គាត់ដល់សាធារណៈជននោះទេ ។ ចំពោះចំណុចទីពីរ មេធាវីការពារក្តីបញ្ជាក់ថា ជាទូទៅ ក្រុមរបស់គាត់មិនត្រូវបានអនុញ្ញាតឱ្យជួបជាមួយកូនក្តីរបស់ខ្លួននោះទេ ។ ក្រុមរបស់គាត់នឹងព្យាយាមជួបជាមួយកូនក្តីរបស់គាត់នៅល្ងាចនេះ ។

**ការផ្អាកកិច្ចដំណើរការសវនាការរហូតដល់ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១២**

អង្គជំនុំជម្រះប្រកាសផ្អាកដំណើរការសវនាការ ដោយលើកទៅបន្តនៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១២ ។ អង្គជំនុំជម្រះបានបញ្ជាក់ថា សវនាការនៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១២ នឹងត្រូវចែកចេញ

ជាពីរផ្នែក ។ ផ្នែកទីមួយនឹងពិភាក្សាអំពីបញ្ហាស្ថានភាពសុខភាពរបស់លោក អៀង សារី និងលទ្ធភាពរបស់គាត់ក្នុងការអង្គុយក្នុងសាលសវនាការ។ ផ្នែកទីពីរ៖ អង្គជំនុំជម្រះនឹងធ្វើសវនាការដោយស្តាប់នូវសក្ខីកម្មរបស់សាក្សី TCW-487 ប្រសិនបើលោក អៀង សារី អាចចូលរួមដំណើរការសវនាការបាន ។ អង្គជំនុំជម្រះបញ្ជាក់ថា អង្គជំនុំជម្រះក៏មានបំណងធ្វើសវនាការនៅថ្ងៃសុក្រ ទី ២៥ ខែ ឧសភា ឆ្នាំ ២០១២ ផងដែរ ។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អង្គជំនុំជម្រះសម្រេចផ្អាកកិច្ចដំណើរការសវនាការ ហើយសវនាការនឹងលើកទៅបន្តនៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១២។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១២។

**<u>កាលបរិច្ឆេទបន្តសវនាការ៖</u>**

សវនាការនឹងបន្តនៅថ្ងៃ ពុធ ទី ២៣ ខែ ឧសភា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ឌុច ឆារី** **Matteo CRIPPA**